ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ច
## របស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៦ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

## សម្រេច

**ប្រការ ១**: កំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូនរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចតទៅៈ

១- ឯកឧត្តម **សុខ ចិន្តាសោភា** ទទួលបន្ទុកជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- ឯកឧត្តម **ម៉ម សារិន** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងកិច្ចការសម្របសម្រួល ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងអង្គការនីតិបញ្ញត្តិ

៣- ឯកឧត្តម **ស្រី ថាមរុង** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងការសម្របសម្រួលកិច្ចការទំនាក់ទំនងអន្តរជាតិ

៤- ឯកឧត្តម **ឈៀង យ៉ាំណារ៉ា** ទទួលបន្ទុកជាអគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

៥- ឯកឧត្តម **យូ ស៊ុនឡុង** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការសន្តិសុខ និងចារកម្ម

៦- ឯកឧត្តម **សោម សឿន** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងការសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងបណ្តាគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល

៧- ឯកឧត្តម **សុន គន្ធរ** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការសហគ្រាសធុនតូច និងមធ្យម និងមីក្រូហិរញ្ញវត្ថុ

៨- ឯកឧត្តម **ហ្សាការីយ៉ា អាដាម** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការសាសនា



www.pheakdeylaw.com

៩- ឯកឧត្តម **កៅ គីមហួន** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការបរទេស និងអាស៊ាន

១០- ឯកឧត្តម **អ៊ុង គីមអន** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ

១១- ឯកឧត្តម **កែវ រ៉េមី** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការសិទ្ធិមនុស្ស

១២- ឯកឧត្តម **ស្វាយ ស៊ីថា** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការប្រតិកម្មរហ័ស

១៣- ឯកឧត្តម **ផៃ ស៊ីផាន** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការនាំពាក្យរាជរដ្ឋាភិបាល

១៤- ឯកឧត្តម **កែវ រតនៈ** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការវិស័យអគ្គិសនី

១៥- ឯកឧត្តម **ហ៊ុន ស៊ីថា** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ

១៦- ឯកឧត្តម **ឈឹម ផលវរុណ** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការសាធារណៈមតិ និងជាប្រធានលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់

១៧- ឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត** ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី និងជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រី ប្រគល់ជូនតាមករណីនីមួយៗ

១៨- ឯកឧត្តម **ហារី សំអាត** ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ ។

១៩- ឯកឧត្តម **កែវ ចាន្ធិ** ទទួលបន្ទុកជួយសម្តេចតេជោនាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ

**ប្រការ ២**: រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៣**: រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ០១ រូបៗ មានជំនួយការ ០៤ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើ អគ្គនាយក, ០១ រូប មានឋានៈស្មើ អគ្គនាយករង និង ០២ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**ប្រការ ៤**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥**: ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ១ និងប្រការ ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com